ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០៤៥...............សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការណែនាំអនុវត្ត
## អនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យអាទិភាព

---

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យអាទិភាព
- បានឃើញប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

## សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងណែនាំអនុវត្តអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាពឱ្យមានប្រសិទ្ធភាព។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់នីតិវិធី លក្ខខណ្ឌ យន្តការ និងទម្រង់នានាពាក់ព័ន្ធនឹងការផ្ដល់ការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព។

**ប្រការ ៣.- វិសាលភាព**

ការលើកទឹកចិត្តផ្នែកពន្ធដារដូចមានចែងក្នុងប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះ សហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យអាទិភាព ដូចខាងក្រោម÷

១- ផលិតផលកសិកម្ម ឬកសិ-ឧស្សាហកម្ម

២- ផលិត និងកែច្នៃម្ហូបអាហារ

៣- កម្មន្តសាលដែលផលិតទំនិញប្រើប្រាស់ក្នុងស្រុក, កែច្នៃកាកសំណល់, និងផលិតទំនិញសម្រាប់វិស័យទេសចរណ៍

៤- កម្មន្តសាលដែលផលិតនូវផលិតផលសម្រេច ឬផ្នែកឬគ្រឿងបង្គុំ ដើម្បីផ្គត់ផ្គង់ឱ្យកម្មន្តសាលដទៃទៀត

៥- ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រួមទាំងការផ្គត់ផ្គង់សេវាគ្រប់គ្រងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានលក្ខណៈនវានុវត្តន៍

៦- សហគ្រាសដែលស្ថិតក្នុងតំបន់ប្រមូលផ្ដុំសហគ្រាធុនតូច និងមធ្យម, និងសហគ្រាសដែលអភិវឌ្ឍតំបន់នេះ។

វិស័យអាទិភាពខាងលើនេះ មិនរួមបញ្ចូលវិស័យដែលប៉ះពាល់ដល់ សន្តិសុខសង្គម សុខភាព និងបរិស្ថាន។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ÷

១- ពាក្យ "សហគ្រាសធុនតូច" សំដៅដល់សហគ្រាសអាជីវកម្មគ្រប់ប្រភេទ ដែលមានផលរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល ដល់ ៧០០ លានរៀល ឬសហគ្រាសដទៃទៀតដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធតូច ស្របតាមច្បាប់និងបទប្បញ្ញត្តិស្ដីពីពន្ធដារ ឬ មានចំនួននិយោជិតចាប់ពី ១០នាក់ ទៅ ៥០នាក់។

២- ពាក្យ "សហគ្រាសធុនមធ្យម" សំដៅដល់សហគ្រាសអាជីវកម្មគ្រប់ប្រភេទ ដែលមានផលរបរប្រចាំឆ្នាំចាប់ពី ៧០០ លានរៀល ដល់ ៤ ០០០ លានរៀល ឬ សហគ្រាសដទៃទៀតដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធមធ្យម ស្របតាមច្បាប់និងបទប្បញ្ញត្តិស្ដីពីពន្ធដារ ឬ មានចំនួននិយោជិតចាប់ពី ៥១នាក់ ទៅ ១០០នាក់។

លក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌ១ និង២ នៃប្រការនេះ ត្រូវបានប្រើប្រាស់សម្រាប់តែគោលដៅលើកទឹកចិត្តផ្នែកពន្ធដារតែប៉ុណ្ណោះ។

**ប្រការ ៥.- ការលើកទឹកចិត្តផ្នែកពន្ធដារ**

សហគ្រាសធុនតូចនិងមធ្យម ដូចមានចែងក្នុងប្រការ ៣ និង ៤ នៃប្រកាសនេះ ត្រូវទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ ដូចខាងក្រោម÷

១- លើកលែងពន្ធលើប្រាក់ចំណូលចំនួន ៣ (បី) ឆ្នាំ ដោយគិតចាប់ពីថ្ងៃដែលចុះបញ្ជីពន្ធដារសម្រាប់សហគ្រាសចុះបញ្ជីថ្មី ឬ ចាប់ពីថ្ងៃដែលសហគ្រាសមកធ្វើបច្ចុប្បន្នភាពសម្រាប់សហគ្រាសដែលបានចុះបញ្ជីពន្ធដាររួចហើយ ចាប់ពីពេលប្រកាសនេះចូលជាធរមាន ឬ

២- លើកលែងពន្ធលើប្រាក់ចំណូលចំនួន ៥ (ប្រាំ) ឆ្នាំ ដោយគិតចាប់ពីថ្ងៃដែលចុះបញ្ជីពន្ធដារសម្រាប់សហគ្រាសចុះបញ្ជីថ្មី ឬ ចាប់ពីថ្ងៃដែលសហគ្រាសមកធ្វើបច្ចុប្បន្នភាពសម្រាប់សហគ្រាសដែលបានចុះបញ្ជីពន្ធដាររួចហើយ ចាប់ពីពេលប្រកាសនេះចូលជាធរមាន ដែលបានបំពេញលក្ខខណ្ឌណាមួយ ដូចខាងក្រោម÷

ក- ប្រើវត្ថុធាតុដើមក្នុងស្រុក ចាប់ពី ៦០% ឡើងទៅ ឬ

ខ- បង្កើនចំនួននិយោជិតបន្ថែមយ៉ាងតិច ២០% ឬ

គ- មានទីតាំងក្នុងតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម (SME Cluster) ។

៣- លើកលែងការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា ក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល។

៤- លើកទឹកចិត្តចំណាយដែលអាចកាត់កងបាន ដូចខាងក្រោម÷

ក- អនុញ្ញាតកាត់កងចំណាយ ២០០% ចំពោះចំណាយលើការប្រើប្រាស់បញ្ជីគណនេយ្យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ខ- អនុញ្ញាតកាត់កងចំណាយ ២០០% ចំពោះចំណាយលើការបណ្តុះបណ្តាលការកាន់បញ្ជីគណនេយ្យ ឬ ការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់និយោជិត

គ- អនុញ្ញាតកាត់កងចំណាយ ១៥០% ចំពោះចំណាយវិនិយោគលើម៉ាស៊ីន ឬ ឧបករណ៍បច្ចេកវិទ្យាមានលក្ខណៈនវានុវត្តន៍ សម្រាប់បម្រើនិងលើកកម្ពស់ផលិតភាពផលិតកម្ម។

## ប្រការ ៦.- លក្ខខណ្ឌនៃការទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ

សហគ្រាសធុនតូចនិងមធ្យមដែលអាចទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ ត្រូវមានលក្ខខណ្ឌ ២ ដូចខាងក្រោម÷

១- ចុះបញ្ជីពន្ធដារ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស នៅរដ្ឋបាលសារពើពន្ធ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

២- ជាសហគ្រាសស្ថិតក្នុងវិស័យអាទិភាព ដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ។

## ប្រការ ៧.- នីតិវិធីនៃការស្នើសុំការលើកទឹកចិត្តផ្នែកពន្ធដារ

នីតិវិធីនៃការស្នើសុំលើកទឹកចិត្តផ្នែកពន្ធដារមានដូចខាងក្រោម÷

១- សហគ្រាសដែលចុះបញ្ជីថ្មី÷ នៅពេលចុះបញ្ជីពន្ធដារ ម្ចាស់សហគ្រាសត្រូវបំពេញទម្រង់ស្នើសុំការលើកទឹកចិត្តផ្នែកពន្ធដារ តាមរយៈ គេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ http://www.tax.gov.kh ឬបំពេញដោយដៃលើទម្រង់ SMEs TIC ដែលផ្តល់ដោយរដ្ឋបាលសារពើពន្ធ។

២- សហគ្រាសដែលបានចុះបញ្ជីរួចហើយ÷ ម្ចាស់សហគ្រាសត្រូវបំពេញទម្រង់ស្នើសុំការលើកទឹកចិត្តផ្នែកពន្ធដារ តាមរយៈ គេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ http://www.tax.gov.kh ឬបំពេញដោយដៃលើទម្រង់ SMEs TICដែលផ្តល់ដោយរដ្ឋបាលសារពើពន្ធ ហើយធ្វើការស្នើសុំនៅអគ្គនាយកដ្ឋានពន្ធដារ ឬ សាខាពន្ធដារខេត្ត-ខណ្ឌ។

## ប្រការ ៨.- ការឆ្លើយតបចំពោះការស្នើសុំលើកទឹកចិត្តផ្នែកពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារត្រូវពិនិត្យនិងសម្រេចលើការស្នើសុំលើកទឹកចិត្តផ្នែកពន្ធដារ និងជូនដំណឹងទៅសហគ្រាសក្នុងរយៈពេលពី ៧ថ្ងៃ ទៅ ១០ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលការស្នើសុំ។ ក្នុងករណីសហគ្រាសគ្មានលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៦នៃប្រកាសនេះ ឬពុំបានផ្តល់ឯកសារគ្រប់គ្រាន់តាមការតម្រូវ អគ្គនាយកដ្ឋានពន្ធដារ អាចបដិសេធការស្នើសុំលើកទឹកចិត្តផ្នែកពន្ធដារ។

## ប្រការ ៩.- ភារកិច្ចសារពើពន្ធ

សហគ្រាសធុនតូចនិងមធ្យម ត្រូវកាន់បញ្ជីគណនេយ្យ និងដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ទៅតាមកាលកំណត់ជូនរដ្ឋបាលសារពើពន្ធ ទោះបីជាត្រូវបានលើកលែងពន្ធលើប្រាក់ចំណូល ដូចមានចែងក្នុងប្រការ ៥ នៃ

ប្រកាសនេះក៏ដោយ និងត្រូវដាក់លិខិតប្រកាសបង់ពន្ធអាករដទៃទៀត ប្រចាំខែ និងប្រចាំឆ្នាំ តាមច្បាប់និងបទប្បញ្ញត្តិ ស្ដីពីពន្ធដារជាធរមាន។

**ប្រការ ១០.- ការដកហូតការលើកទឹកចិត្ត**

១- ការលើកទឹកចិត្តដែលផ្ដល់ជូនដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ ត្រូវបានដកហូត ក្នុងករណី÷

ក- សហគ្រាសមិនបានបំពេញកាតព្វកិច្ចសារពើពន្ធ ដូចមានចែងក្នុងប្រការ ៩ នៃប្រកាសនេះ

ខ- សកម្មភាពអាជីវកម្មដែលជាកម្មវត្ថុនៃការស្នើសុំការលើកទឹកចិត្តផ្នែកពន្ធដារត្រូវបានប្រែប្រួលខុសពី សកម្មភាពអាជីវកម្មក្នុងវិស័យអាទិភាពដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ

គ- ផ្លាស់ប្ដូរអាសយដ្ឋាន ឬម្ចាស់សហគ្រាសដោយមិនបានជូនដំណឹង មករដ្ឋបាលសារពើពន្ធ។

២- ក្នុងករណីការលើកទឹកចិត្តផ្នែកពន្ធដារត្រូវបានដកហូត សហគ្រាសត្រូវទទួលរងនូវទោសទណ្ឌតាមច្បាប់ និង បទប្បញ្ញត្តិស្ដីពីពន្ធដារជាធរមាន។

**ប្រការ ១១.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១២.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធាន គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៨ រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- ដូចប្រការ ១២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# នីតិវិធីនៃការស្នើសុំការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់អ្នកជាប់ពន្ធតូចនិងមធ្យម ក្នុងវិស័យអាទិភាព

**1**

**អ្នកជាប់ពន្ធតូចនិងមធ្យម**

- **ការដាក់ពាក្យស្នើសុំតាមប្រព័ន្ធអនឡាញ**
  - ចុះឈ្មោះបង្កើតគណនីដើម្បីធ្វើការស្នើសុំការលើកទឹកចិត្តពីគេហទំព័រ របស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh
  - ជ្រើសរើសប្រភេទនៃការស្នើសុំការលើកទឹកចិត្តផ្នែកពន្ធដារ
  - បំពេញព័ត៌មានលើពាក្យស្នើសុំ
  - បោះពុម្ពពាក្យស្នើសុំ និងភ្ជាប់នូវសំណុំឯកសារតម្រូវ តាម Checklist
- **ការដាក់ពាក្យស្នើសុំតាមទម្រង់ដោយដៃ**
  - ទាញយកពាក្យស្នើសុំ ដែលមាននៅលើគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh ឬយកពាក្យស្នើសុំនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ
  - បំពេញព័ត៌មានលើពាក្យស្នើសុំ និងភ្ជាប់នូវសំណុំឯកសារតម្រូវតាម Checklist

**2**

**នាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ឬ សាខាពន្ធដារខេត្ត-ខណ្ឌ**

- កត់ត្រា និងវាយបញ្ចូលពត៌មានក្នុងប្រព័ន្ធគ្រប់គ្រង និងតាមដានឯកសារ (Document Tracking System) ដោយមានបិទបារកូដសម្រាប់តាមដាន
- សម្រាប់សាខាពន្ធដារខេត្ត-ខណ្ឌត្រូវបញ្ជូនពាក្យស្នើសុំនិងសំណុំឯកសាររបស់អ្នកជាប់ពន្ធទៅនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ

**សម្រាប់សហគ្រាសចុះបញ្ជីពន្ធដារថ្មី÷** នាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ត្រូវធ្វើការត្រួតពិនិត្យនិងរៀបចំនីតិវិធីផ្តល់ការលើកទឹកចិត្តនៅក្នុងពេលតែមួយជាមួយការចុះបញ្ជីពន្ធដារ ដើម្បីជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ ពិនិត្យសម្រេច

**3**

**នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម**

- ពិនិត្យ និងផ្ទៀងផ្ទាត់សំណុំឯកសាររបស់អ្នកជាប់ពន្ធ
- ពិនិត្យលម្អិតលើកាតព្វកិច្ចសារពើពន្ធ
- ចុះពិនិត្យដល់ទីតាំង និងស្នើសុំកិច្ចសហការពីសាខាពន្ធដារ (ក្នុងករណីចាំបាច់)
- រៀបចំកំណត់បង្ហាញជូនថ្នាក់ដឹកនាំដើម្បីពិនិត្យ និងសម្រេច

**4**

**ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ**

ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារពិនិត្យ និងសម្រេចលើសំណុំឯកសារនៃការស្នើសុំការលើកទឹកចិត្តផ្នែកពន្ធដារ

**កំណត់សម្គាល់÷**

អគ្គនាយកដ្ឋានពន្ធដារត្រូវពិនិត្យនិងសម្រេចលើការស្នើសុំលើកទឹកចិត្តផ្នែកពន្ធដារ និងជូនដំណឹងទៅសហគ្រាសក្នុងរយៈពេលចន្លោះពី ៧ថ្ងៃ ទៅ ១០ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលការស្នើសុំ។